# ២

# ការងាររបស់ខ្ញុំក្នុងជួររដ្ឋាភិបាលក្នុងនាមខ្ញុំជាតំណាងរាស្ត្រ

ក្នុងពាក់កណ្តាលឆ្នាំ១៩៦២ ខ្ញុំបានជាប់ជាតំណាងរាស្ត្រនៃគណបក្សសង្គមរាស្ត្រនិយមនៅមណ្ឌលស្អាង ក្នុងខេត្តកណ្តាល។ ខ្ញុំត្រូវគេតែងតាំងឲ្យធ្វើជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ក្នុងរដ្ឋាភិបាលព្រះអង្គម្ចាស់ នរោត្តមកន្តុល ។

នៅក្នុងរដ្ឋាភិបាល ខ្ញុំបានសាកល្បងរួមវិភាគទានដោះស្រាយបញ្ហាសេដ្ឋកិច្ចជាបន្ទាន់បំផុតមួយក្នុងចំណោមបញ្ហាសេដ្ឋកិច្ចដ៏ច្រើនទៀតរបស់ប្រទេសយើងគឺ ការបាត់បង់តុល្យភាពក្រៅប្រទេសនិងការកេងបន្លំរូបិយប័ណ្ណជាតិ ។

ដូចដែលខ្ញុំបានលាតត្រដាងនៅក្នុងនិក្ខេបបទរបស់ខ្ញុំស្រាប់ បញ្ហាការបាត់បង់តុល្យភាពនៃប្រាក់ចំណាយរបស់ប្រទេសយើង គឺជាការឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងប្រទេសទាំងមូល, មានជាអាទិ ៖

១/វិស័យកសិកម្មជាទូទៅនៅមានភាពអន់ថយនៅឡើយ ហើយត្រូវគ្រប់សង្កត់ដោយរបបបុលបណ្តាក់ដែលមានអត្រាការប្រាក់ខ្ពស់ហួសប្រមាណ ។

២/កូនឧស្សាហកម្មតូចតាចដែលនៅទន់ខ្សោយនិងអស្ថេរភាពនៅឡើយ មានមែកជាងស្ថិតនៅក្រៅប្រទេស ដែលមិនមែនជារបស់ជាតិ ។

៣/ប្រាក់ចំណេញមួយភាគធំត្រូវនាំចេញទៅក្រៅប្រទេស ដូច្នេះធ្វើឲ្យមានការបាត់បង់កំណើននៃការបន្តាក់ទុនដែលមានអំណោយផលល្អដ៏កម្រក្នុងប្រទេស។

៤/អតុល្យភាពនៃការដោះដូរសេដ្ឋកិច្ច ដោយការចុះតម្លៃជាប្រចាំនៃផលិតផលដែលជាវត្ថុធាតុដើមនាំយកទៅលក់នៅក្រៅប្រទេសដូចជា កៅស៊ូ ស្រូវ ពោត ។ល។ ព្រមជាមួយនឹងការឡើងថ្លៃឥតឈប់ឈរនៃទំនិញឧស្សាហកម្មនាំចូលមកក្នុងប្រទេស បណ្តាលឲ្យមានគម្លាតតម្លៃផលិតផលទាំងពីរជាខ្លាំង ។

៥/ការរីកធំហួសហេតុនៃតតិយវិស័យ ដែលធ្វើប៉ះពាល់ដល់ផ្នែកពីរទៀត គឺបឋមវិស័យ(កសិកម្ម) និងទុតិយវិស័យ(សិប្បកម្ម/ឧស្សាហកម្ម), ដែលបង្ករលក្ខណៈឲ្យមានការកើនឡើងនៃការរត់ពន្ធកេងបន្លំរូបិយប័ណ្ណគ្រប់រូបភាព ដោយមានការចូលរួមយ៉ាងសកម្មពីប្រព័ន្ធធនាគារមួយចំនួន ។

©រក្សាសិទ្ធិគ្រប់យ៉ាង
http://www.amekhmer.org

នៅក្នុងនិក្ខេបបទរបស់ខ្ញុំៗក៏បានបញ្ជាក់ផងថា ជំនួយអាមេរិកកាំងមិនបានជួយឲ្យមានការប្រែប្រួលអ្វីដល់ទម្រង់បែបនេះ ដែលមិនអាចបង្កើឲ្យមានការរីកលូតលាស់ឯករាជ្យសេដ្ឋកិច្ចនៃប្រទេសយើងទេ តែអ្វីដែលជាភាពអវិជ្ជមាននោះគឺ ជំនួយទាំងនោះមានរូបភាពជាឥណទានសម្រាប់ឲ្យកម្ពុជានាំទំនិញបរទេសមកលក់នៅក្នុងប្រទេស។ ឧទាហរណ៍ដូចជាក្នុងប្រាក់ឥណទានចំនួន១២៣លានដុល្លារ, ដែល៧៩%នៃទឹកប្រាក់សរុបត្រូវបានប្រើប្រាស់តាមទម្រង់បែបនេះឯង។ ឯប្រាក់ដែលបានមកពីការលក់ទំនិញនេះត្រូវបញ្ជូនទៅក្នុងមូលនិធិមួយសម្រាប់ផ្គត់ផ្គង់ចំណាយយោធា(៦៦%) និងចំណាយខាងការកសាងសេដ្ឋកិច្ច(៣៤%) ។ មិត្តអ្នកអានអាចយល់ហើយថា ក្នុងទម្រង់បែបនេះ ជំនួយនេះធ្វើឲ្យកម្ពុជាពឹងផ្អែកទាំងស្រុងលើសហរដ្ឋអាមេរិក។ ទាំងនេះ គឺអ្វីៗដែលខ្ញុំបានសរសេរពីទិដ្ឋភាពនេះ ៖

“ ទំនិញដែលនាំចូលក្នុងនិទ្ទេសបទជាជំនួយអាមេរិកកាំង មានទម្រង់ជាការឃោសនាពាណិជ្ជកម្ម ក្នុងគោលដៅជម្រុញឲ្យមានចំណង់ និងសេចក្ដីត្រូវការរបស់ប្រណិតៗពីស្រទាប់សង្គមខ្មែរមួយចំនួនដែលតម្រូវតាមការរស់នៅបែបអាមេរិកកាំង។ ជាលទ្ធផលនៃជំនួយនេះ គឺកំណើននៃការហូរចូលជាបន្តបន្ទាប់នៃផលិតផលមិនចាំបាច់ដូចជា រថយន្តប្រណិតៗនិងគ្រឿងបរិក្ខារមួយចំនួន ដែលមានតម្លៃ៣,៨លានដុល្លា (៦,៦% នៃប្រាក់ជំនួយសរុប) ។ បន្ទាប់មកគឺ គ្រឿងប្រើប្រាស់ទំនើបដូចជា ទូទឹកកក, វិទ្យុ, ដែលគិតជាទឹកប្រាក់ស្មើនឹង២,៣លានដុល្លា (៤%នៃប្រាក់ជំនួយសរុប) ។ ផលិតផលប្រើប្រាស់ជាប្រចាំទាំងអស់នេះ សុទ្ធតែតម្រូវឲ្យមានការនាំចូលទំនិញបន្ទាប់បន្សំផ្សេងៗទៀតដូចជាប្រេងឥន្ទនៈ, គ្រឿងផ្សំ, គ្រឿងបន្លាស់ផ្សេងៗទៀត ។ល។

ជំនួយនេះបណ្ដាលឲ្យមានការបះពាល់ជាច្រើនដល់ទិសដៅនៃពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ។ ក្នុងអំលុងឆ្នាំ១៩៤៦-១៩៥៤, សហរដ្ឋអាមេរិកបានចូលរួមចំណែកក្នុងពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាតែ១១%ប៉ុណ្ណោះ ។ សម្រាប់ឆ្នាំ១៩៥៥-១៩៥៧, ស្ថិតិដែលកត់ត្រាដោយក្រសួងគយនិងពន្ធដារបានបង្ហាញថា ការរួមចំណែកក្នុងពាណិជ្ជកម្មក្រៅប្រទេសកម្ពុជារបស់សហរដ្ឋអាមេរិកមានកំណើនរហូតដល់១២,៣%(?) គឺ ៧,៥៤%នៃការនាំចូល និង ១៧,២៤% នៃការនាំចេញ។ ប៉ុន្តែតួលេខទាំងនេះមិនបានរាប់បញ្ចូលផលិតផលអាមេរិកកាំងដែលហូរចូលពី ហុងកុង, សិង្ហបូរី, វៀតណាមខាងត្បូង, ថៃឡង់ដ៍, ឥណ្ឌូណេស៊ី ទេ (ជាអាទិ ផលិតផលប្រេងឥន្ទនៈជាកម្មសិទ្ធិនៃក្រុមហ៊ុន “កាល់តិច” ។ បើរាប់បញ្ចូលផលិតផលទាំងនេះឃើញថា ទំនិញដែលនាំចូលពីអាមេរិកឬ ក្រុមហ៊ុនអាមេរិកកាំងដែលតាំងនៅប្រទេសផ្សេងៗនៅអាស៊ីបានកើនយ៉ាងតិចដល់៤០% នៃការនាំចូលនៃកម្ពុជា។ ដោយឡែក ប្រទេសបារាំងដែលធ្លាប់នាំផលិតផលមកកម្ពុជារហូត៦០% នៃការនាំចូលរបស់កម្ពុជាមុនឆ្នាំ១៩៥៤, បានធ្លាក់ចុះរហូតនៅសល់ត្រឹម២០%។ ហើយខ្ញុំសរុបសេចក្ដីមកថា “វាពិតជាមានការផ្លាស់ប្ដូរដែននៃអភិភវនៃពិតប្រាកដណាស់” ។

អ្វីៗដែលខ្ញុំសរសេរជាខាងក្រោមដោយឈរលើទស្សនៈសេដ្ឋកិច្ច បានគូសបញ្ជាក់យ៉ាងច្បាស់ពីរូបភាពសង្គមខ្មែរជំនាន់នោះ ដែលទស្សនៈទាំងនេះក៏ត្រូវលោក វីលីយាំ-ហ្សូវក្រូស យកមកបញ្ជាក់ប៉ុន្មានឆ្នាំក្រោយមានមកដូចតទៅ ៖

"នៅក្នុងអំលុងទសវត្សរ៍៥០និង៦០ ប្រទេសកម្ពុជាស្ថិតនៅជាសង្គមជនបទជាទូរទៅ ដែលកសិករភាគច្រើនធ្វើអជីវកម្មនៅលើដីផ្ទាល់ខ្លួនរបស់គេ ។ ប៉ុន្តែចាប់ពីឆ្នាំ ១៩៦៣ មក, អាមេរិកបានផ្តត់ផ្គង់រហូតដល់១៤% នៃប្រាក់ចំណូលរបស់កម្ពុជា និង ៣០%នៃថវិការយោធារបស់កម្ពុជា ។ តាមការពិតជំនួយទាំងនេះវាមិនច្រើនហូរហៀរនោះទេ តែបានជះប្រតិឃាតយ៉ាងខ្លាំង ជាពិសេសនៅភ្នំពេញដែលទីនោះមានវត្តមានពួកអាមេរិកកាំងនៅច្រើន ដែលជាហេតុបណ្តាលឲ្យកើតស្រទាប់សង្គមថ្មីមួយដ៏សំខាន់មួយ រាប់ចាប់ពីអ្នកបម្រើក្នុងភោជនីយដ្ឋានរហូតអ្នកបម្រើតាមរោងក្រសាលឬបារ, ជាងជួសជុលយានយន្ត, ជាងជួសជុលម៉ាស៊ីនត្រជាក់, អ្នកធ្វើការក្នុងការិយាល័យ, អ្នករត់ការ, អ្នកបើកឡាន, ស្រីពេស្យា ។ល។ ដោយព្រោះតែកម្រិតជីវភាពរបស់អាមេរិកកាំងខ្ពស់(និងរុងរឿងជាងបារាំង), វត្តមានរបស់គេ ក៏បណ្តាលឲ្យកើនការលោភលន់និងចំណង់នៃពួកអភិជន, ដែលពួកគេបានចំណាយពេលវេលាមួយភាគធំរបស់គេដើម្បីសាងសង់វិឡាប្រណិតៗសម្រាប់ជួលឲ្យពួកបរទេស និងទំនុងត្រាប់តាមការរស់នៅរបស់ជនទាំងនោះផង"។

អ្វីៗដែលខ្ញុំបានសង្ខេបនៅក្នុងនិក្ខេបទរបស់ខ្ញុំដែលថា "មានការប្តូរផ្លាស់ដែនពាណិជ្ជកម្មក្រៅប្រទេសនៃប្រទេសកម្ពុជា" ។ លោក វីលីយាំ-ហ្សូវក្រូស យល់ថា ការប្តូរផ្លាស់នេះ គឺជាការលេចចេញនៃ "ប៉ូលថ្មីនៃការគោរពបូជាក្រៅពីរដ្ឋាភិបាល" ។

ឯលោក មីកាអែល-វិគីរី ក៏ធ្វើការវិភាគមួយស្រដៀងគ្នានេះដែរ៖

"មុនពេលដែលពិភពទំនើបចូលមកជ្រៀតជ្រែកក្នុងជីវិតកម្ពុជា ប្រពន្ធចាស់ហាក់មាន ដំណើរការល្អគួរសមដែរ។ ធនធានដែលពួករដ្ឋការនិងម៉ាស៊ីនរដ្ឋាភិបាលគាបយកពីប្រជាកសិករជាទូទៅមិនបណ្តាលឲ្យមានការប៉ះពាល់ខ្លាំងទៅលើសេដ្ឋកិច្ចជាតិទេ ព្រោះមានការចំណាយតិចតួចបំផុតទៅក្រៅប្រទេស ។

តែលុះដល់ពាក់កណ្តាលសតវត្សទី២០ ប្រពន្ធនេះហាក់ទៅជាចុះខ្សោយនិងទទួលរងសម្ពាធជាខ្លាំង ។ ការប្រើប្រាស់សម្ភារៈប្រណិតរបស់ជនទម្រើសមួយចំនួន លែងឆ្លើយតបនឹងការប្រព្រឹត្តិរបស់សង្គមខាងក្នុង តែទាមទារការនាំចូលផលិតផលដែលមានតម្លៃខ្ពស់ពីបរទេស ដូចជា ការធ្វើដំណើរកំសាន្តនៅបរទេស, បើកគណនីជារូបិយប័ណ្ណដែលមានតម្លៃខ្ពស់($), សាងសង់ផ្ទះសម្បែងតាមគំរូនៃប៉ារីសឬញូវយ៉ក។

ទម្រង់នៃការអភិវឌ្ឍន៍តាមបែបទីក្រុងព្រៃនគរ ឬ បាំងកក ក្នុងអំលុងឆ្នាំ៦០និង៧០ ដែលពួកបស្ចឹមប្រទេស ចាត់ទុកជាវិនាដកម្ម បែរជាត្រូវប្រជាជនខ្មែរមានចំណង់ចង់បានទៅវិញ ។ ហើយក្រុមដែលប្រឆាំងនិងការបដិសេធជំនួយអាមេរិកកាំងរបបស់ស្តេចសីហនុនាឆ្នាំ១៩៦៣-១៩៦៤ បានទាញហេតុផលថា ដោយព្រោះតែស្តេចសីហនុបានបដិសេធជំនួយអាមេរិកកាំង ទើបគេមិនអាចបង្កើតសង្គមបែបនេះបាននៅភ្នំពេញ ។

ជាមួយនឹងរបនាសម្ព័ន្ធនៃសង្គមខ្មែរបែបនេះ វាគ្មានអ្វីពិបាកនឹងទស្សន៍ទាយពីរចនាសម្ព័ន្ធដែលនាំចូលក្នុងប្រទេសនិងសកម្មភាពរីកស្គុះស្គាយនៃផ្នែករត់ពន្ធឬកេងបន្លំរូបិយប័ណ្ណបរទេស ជាពិសេសគឺប្រាក់ដុល្លា ។

មិនតែប៉ុណ្ណោះសូម្បីតែរូបិយប័ណ្ណ ដែលបានចែកចាយសំរាប់នាំទំនិញចូលក្នុងប្រទេស ដូចជាបរិក្ខារោងចក្រនិងកសិកម្ម, ទិញគ្រឿងបន្លាស់ឬទិញជី ក៏ត្រូវគេបង្វែរយកទៅលក់នៅទីផ្សារងងឹតស្ទើរតែអស់ ព្រោះរដ្ឋដូរ១ដុល្លាតែ៣០រៀលទេ តែនៅទីផ្សារងងឹតគេអាចដូរបានរហូត២០០រៀលឯណោះ ។ លោក វិគីរីបានសរសេរថា ៖

“លំដាប់ថ្នាក់ខ្ពស់នៃសង្គមបានធ្វើសម្ពាធទៅលើស្រទាប់សង្គមមធ្យមផ្សេងៗទៀត រហូតដល់ម្នាក់ៗមានចិត្តប្រាថ្នាចង់បានកម្រិតជីវភាពដ៏ប្រណិតមួយ ដែលគ្មាននរណាឬសង្គមណាអាចផ្តល់ឲ្យគេបាន ។ ទីបំផុតវាក៏បណ្តាលឲ្យមានអំពើពុករលួយទូទៅ ដែលធ្វើឲ្យមានការបង្វែរធនធាន ទៅធ្វើការបោះទុនឥតប្រយោជន៍ទៅវិញ”

ដូច្នេះសេដ្ឋកិច្ចជាតិទាំងមូលត្រូវរងការប៉ះពាល់ជាខ្លាំង ។ ប្រទេសក៏ធ្លាក់ខ្លួនជារណបជំនួយបរទេសកាន់តែខ្លាំងឡើងៗ ។ ស្ថានភាពនេះមិនអាចបន្តប្រព្រឹត្តិទៅទៀត ដោយគ្មានការប៉ះពាល់ទៅលើនយោបាយអព្យាក្រិតបានទេ ។

ដូច្នេះតាមរយៈលោក ស៊ីន-សាន, ដែលពេលនោះលោកជាប្រធានធានាគាជាតិ, ខ្ញុំបានលើកស្នើគម្រោងកែទម្រង់សេដ្ឋកិច្ចមួយទៅសម្តេចប្រមុខរដ្ឋ ដើម្បីធ្វើជាតិតូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេសលើផលិតផលសំខាន់ៗមួយចំនួនដូចជា កៅស៊ូ, អង្ករ, ពោត ។ល។, និងធនាគារខ្មែរមួយចំនួនដែលល្បីខាងសកម្មភាពកេងបន្លំរូបិយប័ណ្ណជាតិ ។

ជាការពិត, ទាំងនេះវាគ្រាន់តែជាវិធានការមួយផ្នែកប៉ុណ្ណោះ តែតាមការគិតរបស់ខ្ញុំ វាជាការចាំបាច់ណាស់ទម្រាំតែរដ្ឋាភិបាលយើងសម្រេចចិត្តអនុវត្តន៍តាមវិធានការផ្សេងៗទៀត ដែលខ្ញុំបានណែនាំតាមបែបដែលខ្ញុំបានបញ្ជាក់នៅចុងបញ្ចប់នៃនិក្ខេបទរបស់ខ្ញុំ ។


©រក្សាសិទ្ធិគ្រប់យ៉ាង
http://www.amekhmer.org

ជាអកុសល ដោយបន្ទាប់ពីមានល្បិចកលទុច្ចរិតជាបន្តបន្ទាប់ ខ្ញុំក៏ត្រូវគេដកហូតតំណែង បណ្តាលឲ្យខ្ញុំមិនអាចបន្តកិច្ចការទាំងនោះតទៅទៀតបាន ។ គឺមុនពេលនោះប្រហែលមួយខែ ក្នុងឱកាសមានចលនាបាតុកម្មនិស្សិតមួយនៅសៀមរាប, លោក លន់-ណុល បានធ្វើបញ្ជីមនុស្ស៣៤នាក់ ដែលត្រូវចាប់ចង(នៅក្នុងនោះមានរូបខ្ញុំដែរ) ប៉ុន្តែពេលនោះ ស្តេចសីហនុក៏បានធ្វើអន្តរាគមមិនឲ្យរឿង នោះបែកវែងឆ្ងាយតទៅទៀត ។ បន្ទាប់មកមានឧបាយកលសម្ងាត់មួយទៀត គឺបញ្ហាសាច់គោឡើងថ្លៃ ។ ដោយសាររឿងនេះ សមាជជាតិក៏សម្រេចដកការទុកចិត្តពីខ្ញុំ ដូច្នេះសភាមិចអាចធ្វើអ្វីបានក្រៅពីធ្វើសច្ចាប័នចំពោះការសម្រេចនោះទេ ។ ទោះជាយ៉ាងណា ខ្ញុំមានក៏ការរីករាយដែរ ដោយពីរបីខែក្រោយបន្ទាប់ពីការបញ្ឈប់មុខងាររបស់ខ្ញុំមក គឺនៅចុងឆ្នាំ១៩៦៣ សម្តេចសីហនុក៏បានប្រគល់ការកិច្ចរៀបចំវិធានការ(កែទម្រង់សេដ្ឋកិច្ច) ដែលមានលំនាំប្រហាក់ប្រហែលនឹងគម្រោងរបស់ខ្ញុំដែរ ទៅឲ្យលោក ឯ.ឧ. ស៊ុនសាន ។

លទ្ធផលក៏បានបង្ហាញភ្លាមៗដែរ គឺមានការទប់ស្កាត់លើចរាចរខុសច្បាប់នៃរូបិយប័ណ្ណ ដូច្នេះប្រាក់ដែលបានមកពីការនាំទំនិញទៅលក់ឯក្រៅប្រទេស និង ប្រាក់ដែលបម្រុងទុកក្នុងធនាគារជាតិក៏បានកើនឡើងគួរឲ្យកត់សម្គាល់ចាប់ពីឆ្នាំ១៩៦៤ ភ្លាមដែរ ។ ធនាគារដ៏ធំមួយដែលមានឈ្មោះថា "ធនាគារភ្នំពេញ" ក៏ត្រូវរលំ ។ ម្ចាស់ធនាគារឈ្មោះ សុង សាក់កិត្យប៉ាណិច ដែលគេឯងបានដឹងគ្រប់គ្នាថា ធ្លាប់មានទំនាក់ទំនងជាមួយ សេ-អ៊ី-អា និងរដ្ឋាភិបាលវៀតណាម ក៏បានរត់គេចខ្លួនទៅព្រៃនគរបាត់ទៅ...

ក្នុងក្របខ័ណ្ឌការងារខ្ញុំជាតំណាងរាស្ត្រ ខ្ញុំតែងបានទៅប្រាស្រ័យទាក់ទងជាមួយបណ្តាជនក្នុងមណ្ឌលខ្ញុំជាទៀតទាត់ ។ ខ្ញុំបានទៅរហូតដល់កន្លែងចុងកាត់មាត់ញកបំផុត ហើយក៏អាចយល់ដឹងពីបញ្ហាមួយចំនួន មានជាអាទិ ៖

- ពួកថៅកែឡនេសាទ តែងទៅទន្រ្ទានយកបឹងបួរ ស្ទឹង អូរ ដែលរដ្ឋទុកបម្រុងសម្រាប់ប្រជាជននៅតាមភូមិឋាន។
- ពួកថៅកែអស់នោះបានពង្រីងបឹងបួរទាំងឡាយដើម្បីចាប់ត្រី នៅពេលដែលប្រជាជនត្រូវការទឹកទាំងនោះសម្រាប់ធ្វើស្រែប្រាំងរបស់គេ។
- នៅពេលដែលពន្ធដារមានទម្ងន់ធ្ងន់ធ្ងរណាស់ទៅហើយសម្រាប់ប្រជាជនយើង ស្រាប់តែមានបរិវិសកម្ម ជាច្រើនតម្រូវឲ្យគេណ្ឌកៀរប្រជាជនយកទៅធ្វើពលកម្មផ្សេងៗ ។
- អ្នកដែលអាក់ខានមិនបានឆ្លើយតបនឹងបរិវិសកម្មឬកំណែនកម្មនោះត្រូវចាប់ខ្លួនដោយបំពាន

ម្តងទៀតខ្ញុំបានព្យាយាមពាំនាំបណ្តឹងរបស់ប្រជាជនទាំងនោះមកសភា និង បានជួយធ្វើអន្តរាគមជាបន្តបន្ទាប់ជាមួយនឹងក្រសួងពាក់ព័ន្ធនឹងបញ្ហាទាំងនោះ តែខ្ញុំបែរជាទទួលការ ឈ្នានិសស្អប់ខ្ពើមពីពួកគេទៅវិញ ។

ខ្ញុំសូមបន្ថែមថា សូម្បីតែខ្ញុំមានងារជារដ្ឋមន្ត្រីនិងជាតំណាងរាស្ត្រនៅសភាជាតិក៏ដោយ ក៏ខ្ញុំត្រូវភ្នាក់ងារសម្ងាត់នៃក្រសួងប៉ូលិសតាមដានឥតឈប់ឈរ ។ ពួកគេថែមទាំងបានមកបង្ហាញខ្លួនចំពោះខ្ញុំហើយបានសុំខ្ញុំឲ្យប្រាប់ពីចរាចរប្រចាំថ្ងៃរបស់ខ្ញុំ ។

## II
## Mon travail au sein du Gouvernement et en tant que député à l'Assemblée Nationale

Au milieu de l'année 1962, je fus élu député du "Sangkum Reastr Niyum pour la circonscription de Saang, dans la province de Kandal, et nommé Secrétaire d'État au commerce dans le gouvernement du Prince Norodom Kantol.

Au sein du gouvernement, j'essayai d'apporter ma contribution à la solution d'un des problèmes économiques les plus urgents de notre pays : le déficit de la balance extérieure et le trafic des devises étrangères.

Evidemment, comme je l'avais exposé dans ma thèse de doctorat, le déficit de la balance des paiements était plutôt le reflet de l'ensemble de la structure économique du pays:

1° Un vaste secteur agricole arriéré écrasé sous le poids de l'usure.

2'. Des îlots de secteur industriel faibles et instables faisant partie d'un ensemble dont le centre est situé à l'étranger plutôt que d'un ensemble national intégré.

3'. Exportation de la majeure partie des profits à l'étranger, privant l'économie du pays de l'effet de multiplication des rares investissements productifs.

4'. Baisse constante du terme de l'échange, due à la baisse des prix des matières premières exportées sur le marché international (caoutchouc, riz, maïs), parallèle à la hausse constante des prix des produits manufacturés importés, provoquant ainsi un écart de plus en plus grand dans l'échelle des prix des deux principales catégories de produits.

5° Gonflement exagéré du secteur tertiaire au détriment des secteurs primaire et secondaire, créant ainsi un terrain fertile pour les multiples formes de spéculation, avec la participation active du système bancaire.

Dans ma thèse, j'avais également souligné que l'aide américaine n'avait pas contribué à un changement quelconque d'une telle structure, pour permettre un développement indépendant de notre économie. Le côté le plus négatif de cette aide est qu'elle était constituée par des crédits d'importation commerciale. A titre dexemple, sur un crédit total de 123 millions de dollars libéré au cours des exercices 1955-57, 97 millions, soit 79% du total, étaient sous cette forme. La vente de marchandises importées au titre de cette aide alimentait un fonds de contrepartie destiné à financer les dépenses militaires (environ 66%) et les investissements économiques (34%)I . Le lecteur peut bien réaliser que sous cette forme, cette aide visait plutôt à attirer l'économie du Cambodge sous la dépendance des Etats-Unis d'Amérique. Voici à peu près ce que j'écrivais à cet égard :

"Les produits importés sous la rubrique de l'aide américaine apparaissaient plutôt comme des échantillons publicitaires destinés à susciter la demande des produits de luxe et à exciter le désir

« Brochure éditée par la mission de ]'Aide Américaine au Cambodge Résumé exercice 55-57, p. 11 ».

d'une partie de la société khmère à imiter le train de vie américain. Comme résultat de cette aide, une demande d'importation de certains produits non essentiels émerge et ne cesse de se renforcer, notamment l'importation des automobiles, des moteurs et accessoires ($ 3,8 millions, ou 6,6% du total de l'aide), appareils électriques (réfrigérateurs, radios etc ... $ 2,3 millions, ou près de 4% du total de l'aide). Tous ces produits durables de consommation entraînent le besoin futur d'importer des produits subsidiaires : carburants, accessoires et pièces de rechange.

Cette aide n'a pas manqué de produire des effets sur l'orientation du commerce extérieur du Cambodge. Au cours des années 1946-54, les Etats-Unis ne participaient au commerce extérieur cambodgien que pour 11%. Pour les années 1955-57, les chiffres enregistrés par les Douanes et le

service des impôts indirects révèlent que la participation des Etats-Unis au commerce extérieur du Cambodge s'élevait à 12,3% ce qui représente 7, 46% du total des importations cambodgiennes et 17,24% des ses exportations. Ces chiffres négligent cependant l'importation des produits américains en provenance de Hong-Kong, Singapour, du Sud- Vietnam, de Thaïlande, et dIndonésie (dont les produits pétroliers appartiennent à Caltex)... Compte tenu de toutes ces considérations, la valeur des produits américains ou en provenance de firmes américaines installées dans ces divers pays d'Asie s'élèverait à au moins 40% du total des valeurs des importations du Cambodge.

D'autre part, les importations du Cambodge en provenance de la France, qui s'élevaient à 60% des importations cambodgiennes avant 1954 tombent à seulement 20%. "

Et je conclus :

"Il y a donc un net déplacement du pôle de domination. "

Ce que j'ai écrit ci-dessus, en me plaçant du point de vue économique, se trouve bien illustré par le tableau de la société khmère ainsi dépeinte quelques années plus tard par William Shawcross :

« Tout au long des années cinquante et soixante, le Cambodge était resté principalement une société rurale, où la grande majorité des paysans travaillait ses propres terres. Mais vers 1963, les Américains fournissaient au pays environ 14% de son revenu annuel et 30% de son budget militaire. Les sommes en elles-mêmes n'étaient pas exorbitantes, mais elles eurent des répercussions, surtout à Phnom Penh, où la présence des Américains eut pour effet de créer une nouvelle classe sociale importante, allant des garçons de restaurants aux serveuses de bar, mécaniciens auto et réparateurs de climatiseurs, garçons de bureaux, courtiers, chauffeurs, prostituées... Parce que le niveau de vie des Américains était élevé (et plus éclatant que les Français), leur présence exacerbait également la cupidité et l'envie des riches qui passaient une bonne partie de leur temps à construire des villas qu'ils louaient à des fonctionnaires étrangers, à des prix élevés, et 1 à tenter d'imiter leur train de vie et leur style de vie. »

Ce que j'ai résumé dans ma thèse comme "un déplacement du pôle du commerce extérieur du Cambodge", William Shaweross le perçoit comme l'apparition d'un ,nouveau pôle de loyauté en marge du gouvernement"

1 Une tragédie sans importance - p. 52.

C'est enfin une analyse très semblable que développe Michael Vickery, :

"Avant que le monde moderne ne s'insinue dans la vie du Cambodge, l'ancien système fonctionnait plutôt correctement. La richesse extorquée à la paysannerie par les fonctionnaires et la cour l'appareil étatique - ne correspondait pas en général à une perte sèche pour l'économie nationale, car peu en était dépensée hors du pays...

Au milieu du 20ème siècle, cependant, ce système était bien plus fragile et oppressif La consommation de luxe à laquelle s'adonne l'élite ne correspond plus à de la consommation intérieure, mais implique l'acquisition de produits étrangers chers, de fréquents voyages à l'étranger, des comptes en devises fortes, et des propriétés aménagées sur le modèle de Paris ou New York..

La forme de croissance du type de celle de Saigon ou Bangkok dans les années 60 et 70 ... que la plupart des occidentaux considéreraient comme dramatique, était considérée par les Cambodgiens avec envie. Et ceux qui contestaient le rejet de l'aide américaine par Sihanouk en 1963-64 argumentaient que ce rejet rendrait impossible ce mode de développement à Phnom Penh. "

Avec une telle structure de la société khmère, l'on n'a pas de peine pour deviner la structure des importations du

*« L'une tragédie sans importance - p. 54. Cambodia 1975-1982, Michael Vickery, 1984, (ed. Silkwoorms Books, 1999 p. 24)”*

pays et les activités florissantes dans le domaine du trafic des devises étrangères, en particulier du dollar.

Même les devises attribuées pour l'importation des équipements industriels ou agricoles, des pièces de rechange ou des engrais, étaient détournées vers le marché noir où le dollar se vendait à plus de 200 riels, alors que le taux officiel n'était que de 30 riels. Comme l'écrit encore M. Vickery:

"Des échelons les plus élevés de la société, l'effet d'entraînement s'est répandu sur les échelons intermédiaires, jusqu'à ce que chacun aspire à un niveau de luxe que ni les individus, ni la société dans son ensemble, ne pouvaient s'offrir. Il en résulta une corruption généralisée, et le détournement des richesses vers des investissements improductifs"

L'ensemble de l'économie en souffrait donc énormément. Le pays devenait de plus en plus tributaire des aides extérieures. Cette situation ne pouvait continuer sans porter atteinte à la politique de neutralité.

Par l'intermédiaire de S.E. Son Sann, alors président de la Banque Nationale, je soumis donc au Prince chef de l'Etat un plan pour une réforme économique tendant à la nationalisation du commerce extérieur des principaux produits : caoutchouc, riz, mais.... et des banques cambodgiennes connues pour leurs activités au service de la spéculation.

Certes, ce n'étaient que des mesures partielles, mais elles s'avéraient à mon avis nécessaires en vue de parer au plus pressé en attendant que nos dirigeants d'alors se convainquent des mesures complémentaires dans le sens que j'avais suggéré en conclusion de ma thèse.

Malheureusement, à la suite d'une série d'intrigues, je fus relevé de mon poste et ne pus achever mon travail. Déjà, quelques mois auparavant, à l'occasion des manifestations des élèves à Siem Reap', Lon No12 avait établi une liste de 34 personnes (dont moi-même), qui devaient être arrêtées. Mais l'intervention du Prince avait empêché l'affaire d'aller plus loin. Survint ensuite une autre cabale : le "Congrès National'3' me retira sa confiance sous le prétexte bien minime de la hausse du prix du beefsteak4 . Evidemment lAssemblée Nationale ne put qu'entériner la décision.

Néanmoins, je fus toujours content de savoir que, deux ou trois mois après ma relégation, vers la fin de 1963, le Prince confia la charge de procéder à des mesures à peu près dans le même sens à S.E. Son Sann.

*1-Au début la manifestation était tout à fait pacifique. J'en ignorais la cause exacte. Mais il se trouva qu'un (au moins) des jeunes manifestants placés en prde à vue dans un poste de police fut découvert tué, ce qui provoqua plusieurs vagues de protestations plus violentes et plus virulentes à l'égard du Sangkum Reastr Niyum" et du gouvernement.*

*2- Lon Nol était un obscur fonctionnaire, chef d'un tout petit parti (n'ayant mais accédé à la représentation parlementaire), qui monta en surface après noir manifesté sa loyauté au roi Norodom Sihanouk en rejoignant l'armée au moment de la croisade royale pour l'indépendance en 1953. Le succès de la croisade royale contribua à l'éclipse des deux forces qui avaient depuis 1946 levé le drapeau de l'indépendance, à savoir le Parti Démocrate et Son Ngoc Thanh*

*3- Le "Congrès National" était une tentative du Prince Norodom Sihanouk l'appliquer la démocratie directe. N'importe qui pouvait y prendre part, avec kt droit d'y prendre la parole et de participer aux votes. Il laissait ainsi la porte ouverte à bien des intrigues et des manoeuvres politiques.*

*4-Notion en passant qu'il ne s'agissait nullement d'une hausse générale des prix a que la hausse du prix du beefsteak ne put affecter qu'une faible minorité des consommateurs.*

Les résultats s'en firent vite sentir : un frein étant mis sur le trafic de devises, les recettes des exportations, ainsi que les réserves de la Banque Nationale, s'améliorèrent nettement à partir de 1964. Une banque, dénommée « Banque de Phnom Penh », tomba en faillite. Le propriétaire, Song-Sak-Kich Pannich, bien connu pour ses liaisons avec la CIA et l'administration du Sud-Vietnam, s'enfuit pour Saigon...

Dans le cadre de mon travail de député, je rendais régulièrement visite à la population de ma circonscription'. J'allais jusque dans les coins les plus reculés. J'ai pu ainsi me rendre compte de ses problèmes dont voici quelques exemples :

- Les concessionnaires des lots de pêcherie empiétaient constamment sur les lacs, les étangs, les rivières qui avaient été réservés aux villageois.

- Ces concessionnaires asséchaient les lacs et les étangs pour attraper les poissons, alors que la population avait besoin de l'eau pour irriguer leur riz de saison sèche.

-Alors que les impôts pesaient déjà lourd sur la population, des souscriptions se multipliaient ainsi que des corvées pour divers travaux.

- Les manquements à ces souscriptions - ou conscriptions donnaient souvent lieu à des arrestations arbitraires.

Là encore, en m'efforçant de faire entendre les plaintes de la population à l'Assemblée Nationale, ou en intervenant auprès des services concernés, je m'attirais bien des hostilités.

Je voudrais ici ajouter que, même devenu ministre et député à l'Assemblée Nationale, j'étais toujours suivi de près par des agents de la police secrète'. Ces derniers étaient même venus se présenter à moi pour me demander de les prévenir de mes déplacements quotidiens.

*1 La province de Kandal était à cette époque divisée en neuf circonscriptions. si ma mémoire est bonne, Ma circonscription, Saang, était voisine de LoeikDêk (Koh-Thom), dont le député, le Prince Savann Areth, avec lequel je m'étais lié d'amitié, a été assassiné par les forces de Lon Nol juste après le coup d'État.*